**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួលឯកឧត្តម Anatoly BOROVIK ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ**ឯកឧត្តម** Anatoly BOROVIK ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនៅទីស្តីការក្រសួង។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ និងអបអរសាទរ **ឯកឧត្តម** BOROVIK ចំពោះការដែលឯកឧត្តមទទួលបានការតែងតាំងជា **ឯកអគ្គរដ្ឋទូត** សហព័ន្ធរុស្ស៊ីប្រចាំនៅកម្ពុជា។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ពីការត្រៀមផ្តល់កិច្ចសហការពេញលេញ ដល់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ក្នុងការបំពេញបេសកកម្មឲ្យទទួលបានជោគជ័យ ក៏ដូចជាដើម្បីធ្វើឲ្យទំនាក់ទំនងនៃប្រទេសទាំងពីរកាន់តែរីកចម្រើន និងស៊ីជម្រៅបន្ថែមទៀត។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានរំលឹកអំពីប្រវត្តិនៃទំនាក់ទំនងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការដ៏យូរអង្វែងរបស់ប្រទេសទាំងពីរ ក៏ដូចជាប្រវត្តិរបស់ **ឯកឧត្តម ឯកអគ្គរដ្ឋទូត**ដែលធ្លាប់ធ្វើការនៅកម្ពុជាកន្លងមកតាំងពីឆ្នាំ១៩៨៤ ដែលក្នុងន័យនេះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** អាចជាសាក្សីមួយរូបដ៏សំខាន់ចំពោះការវិវឌ្ឍសភាពការណ៍នានា និងការអភិវឌ្ឍនៅប្រទេសកម្ពុជា។

ជាការឆ្លើយតប **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានបង្ហាញនូវក្តីរីករាយដែលបានមកបំពេញបេសកកម្មការទូតនៅកម្ពុជា និងសម្តែងការកោតសរសើរចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានឆ្លងកាត់ការលំបាកនានានៅក្នុងប្រវត្តិសាស្ត្រ ហើយតស៊ូសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងនយោបាយដូចបច្ចុប្បន្ននេះ។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** ក៏បានលើកឡើងផងដែរថា បើប្រៀបធៀបពីឆ្នាំ១៩៨៤មកដល់បច្ចុប្បន្ន កម្ពុជាមានការអភិវឌ្ឍន៍ប្រែប្រួលស្ទើរតែទាំងអស់ លើកលែងតែងចំនុចមួយដែលមិនមានការប្រែប្រួល គឺភាពញញឹមរួសរាយ និងបដិសណ្ឋារកិច្ចរាក់ទាក់របស់ប្រជាជនកម្ពុជាចំពោះភ្ញៀវ និងជនបរទេសដែលនេះជាកត្តាគន្លឹះក្នុងការទាក់ទាញ វិនិយោគិនបរទេសក៏ដូចជាភ្ញៀវទេសចរណ៍ ឲ្យមកវិនិយោគ និងទស្សនានៅកម្ពុជា។

ពាក់ព័ន្ធនិងទំនាក់ទំនងជិតស្និទ្ធរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ប្រទេសទាំងពីរ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញអំពីការជួបគ្នាជាញឹកញ៉ាប់រវាង **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាមួយ **ឯកឧត្តមប្រធានាធិបតី** Vladimir Putin ក៏ដូចជាជាមួយអតីតៈប្រធានធិបតី និងនាយករដ្ឋមន្ត្រី Dmitry Medvedev នៅ Moscow, Sochi, នៅភ្នំពេញ និងនៅតាមវេទិការកិច្ចប្រជុំថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ

ផ្សេងៗទៀតផងដែរ។ បន្ថែមលើនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានដឹកនាំទស្សនៈកិច្ចការងារចំនួនពីរលើកទៅ Moscow និងបានធ្វើជាសហប្រធាននៃកិច្ចប្រជុំគណៈកម្មាធិការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ីចំនួនពីរលើកផងដែរ។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានឆ្លើយតបថាថ្នាក់ដឹកនាំរុស្ស៊ីវាយតំលៃខ្ពស់ចំពោះទំនាក់ទំនងរវាងប្រទេសទាំងពីរ និងបានបញ្ជាក់ថា តបតាមការអញ្ជើញរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រីការបរទេស** Sergy Lavrov នឹងអញ្ជើញមកបំពេញទស្សនៈកិច្ចនៅកម្ពុជានៅពេលសភាពការណ៍ Covid-19 បានធូរស្បើយ។

ចំពោះកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថាទំហំផ្លាស់ប្តូរពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានកម្រិតនៅឡើយ ទោះបីជាមានកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នាជាច្រើនត្រូវបានចុះហត្ថលេខារវាងប្រទេសទាំងពីរក៏ដោយ ជាក់ស្តែងក្នុងអណ្តតិរបស់**ឯកឧត្តម ឯកអគ្គរដ្ឋទូត**មុន មានកិច្ចព្រមព្រៀង និងអនុសារណៈយោគយល់គ្នាចំនួយ**៥១**ត្រូវបានចុះហត្ថលេខា។ក្នុងន័យនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានជំរុញឲ្យមានកិច្ចប្រឹងប្រែងបន្ថែមទៀតក្នុងការអនុវត្តនូវកិច្ចព្រមព្រៀងទាំងនោះឲ្យមានប្រសិទ្ធភាពដើម្បីពង្រីកវិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ អប់រំ វប្បធម៌ កសិកម្ម និងវិស័យផ្សេងៗទៀតឲ្យកាន់តែរីកចម្រើន។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានយល់ស្របតាម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និងបានបន្ថែមថា **ឯកឧត្តម** នឹងខិតខំជំរុញ បញ្ចុះបញ្ចូលវិនិយោគិនរុស្ស៊ីអោយមកវិនិយោគនៅកម្ពុជា និងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀតអោយចេញជាផ្លែផ្កាច្បាស់លាស់។

ដោយឡែកពាក់ព័ន្ធលើវិស័យសុខាភិបាល **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់រដ្ឋាភិបាលរុស្ស៊ីចំពោះការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រសម្រាប់ការព្យាបាល និងបង្ការការឆ្លងជំងឺកូវីដ-១៩ ដល់កម្ពុជា។ ទន្ទឹមនឹងនេះ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានអបអរសាទរដល់រុស្ស៊ីដែលបានក្លាយជាប្រទេសដំបូងគេ ក្នុងការសម្រេចបានការរកឃើញវ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ឈ្មោះថា Sputnik V ។ ជាងនេះទៅទៀត **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអរគុណ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** ក៏ដូចជា**រដ្ឋាភិបាលរុស្ស៊ី** លើគំរោងធ្វើទំនើបកម្មមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលជានិមិត្តរូបនៃទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ តាមរយៈការបំពាក់នូវគ្រឿងបរិក្ខារពេទ្យទំនើប និងទាន់សម័យ។

លើកិច្ចសហប្រតិបត្តិការពហុភាគីវិញ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានអរគុណរដ្ឋាភិបាលរុស្ស៊ីដែលបានគាំទ្រកម្ពុជាជាសមាជិកសង្កេតការនៃអង្គការសហប្រតិបត្តិការសៀងហៃ (Shanghai Cooperation Organization) និងជួយកម្ពុជាក្នុងការចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី (Eurasian Economic Union) ដែលនេះពិតជាមានសារៈសំខាន់ដល់ប្រទេសកម្ពុជា ក្នុងការពង្រីកទីផ្សាររបស់ខ្លួន។ **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានឆ្លើយតបថាជានិច្ចកាលកម្ពុជាគឺជាមិត្ត និងជាដៃគូរដែលអាចទុកចិត្តបានរបស់រុស្ស៊ី ហើយថារុស្ស៊ីនឹងជួយគាំទ្រកម្ពុជាក្នុងការចរចា អោយសម្រេចបាននូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយ Eurasian Economic Union ។ បន្ថែមលើនេះទៀត **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានបញ្ជាក់ថា រុស្ស៊ីត្រៀមសហការជាមួយកម្ពុជា លើការងារអាស៊ាន ក៏ដូចជាត្រៀមជួយកម្ពុជា

ក្នុងការរៀបចំកិច្ចប្រជុំកំពូល 13th ASEM Summit ផងដែរ។ ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនផ្សេងទៀតដែលជាកង្វល់និងការចាប់អារម្មណ៍រួម។

គួរឱ្យកត់សម្គាល់ផងដែរ ប្រទេសកម្ពុជានិងសហព័ន្ធរុស្ស៊ី បានភ្ជាប់ទំនាក់ទំនងការទូតក្នុងឆ្នាំ ១៩៥៦ ហើយនៅឆ្នាំ២០២១ ប្រទេសទាំងពីរនឹងប្រារព្ធខួប៦៥ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតរបស់ខ្លួនតាមរយៈការផ្លាស់ប្តូរសារអបអរសាទររបស់ឥស្សរៈជនជាន់ខ្ពស់ទាំងសងខាង និងការរៀបចំព្រឹត្តិការណ៍ផ្សេងៗរួមគ្នាមួយចំនួនដូចជាវប្បធ៌ម សិល្បៈ កីឡា ក៏ដូចជាការជួបជុំផ្សេងៗផងដែរ៕